ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
លេខ ០៩២ ព.ណ.ភ.ញ.ភ.ប្រក

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារចំពោះកិច្ចគ្រប់គ្រង និងតាមដានព័ត៌មានថ្លៃទំនិញនៅលើទីផ្សារ
## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- យោងសេចក្តីសម្រេចលេខ៤៩ សសរ ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១ ស្តីពីការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅ នៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតក្រុមការងារចំពោះកិច្ចគ្រប់គ្រង និងតាមដានព័ត៌មានថ្លៃទំនិញបម្រើជីវភាពប្រចាំថ្ងៃ នៅលើទីផ្សាររបស់ក្រសួងពាណិជ្ជកម្ម ដែលមានសមាសភាពដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម | **ប៉ាន សូរស័ក្តិ** | រដ្ឋមន្ត្រី | ប្រធាន |
| ២- | ឯកឧត្តម | **សុខ សុភ័ក្ត្រ** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៣- | ឯកឧត្តម | **ស៊ុន ដារ៉ាចន្ទ** | រដ្ឋលេខាធិការ និងជានាយកខុទ្ទកាល័យ | សមាជិក |
| ៤- | ឯកឧត្តម | **ស៊ាង ថៃ** | រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យ | សមាជិក |



ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61,Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

| | | | | | |
|---|---|---|---|---|---|
| ៥- | ឯកឧត្តម | **ចាន់** | **សុខនី** | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានអគ្គនាយកក្រុមហ៊ុនហ្គ្រីនត្រេដ | សមាជិក |
| ៦- | ឯកឧត្តម | **ផាន** | **អូន** | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយក ក.ប.ប. | សមាជិក |
| ៧- | ឯកឧត្តម | **ឡាយ** | **សុខសៅគន្ធា** | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ៨- | ឯកឧត្តម | **ភៅ** | **ភោសល** | អគ្គនាយកជំរុញពាណិជ្ជកម្ម | សមាជិក |
| ៩- | លោក | **សំរិទ្ធ** | **សារុភា** | អគ្គនាយកស្តីទីពាណិជ្ជកម្មក្នុងប្រទេស | សមាជិក |
| ១០- | លោក | **ជា** | **រីន** | អគ្គាធិការរង | សមាជិក |
| ១១- | លោក | **ឡុង** | **កែមវិចិត្រ** | អគ្គនាយករងពាណិជ្ជកម្មអន្តរជាតិ | សមាជិក |
| ១២- | លោក | **ពៅ** | **គាងឡេង** | ប្រធានមន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ | សមាជិក |
| ១៣- | លោក | **អោម** | **ប៊ុនធឿន** | ប្រធានមន្ទីរពាណិជ្ជកម្មខេត្តកណ្តាល | សមាជិក |
| ១៤- | លោក | **លឹម** | **ច័ន្ទសុភ័ក្ត្រ** | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍វិស័យឯកជន | សមាជិក |

**ប្រការ២ _**

ក្រុមការងារនេះ មានភារកិច្ចដូចខាងក្រោម៖

- ត្រួតពិនិត្យបរិមាណ និងតាមដានថ្លៃទំនិញដែលបម្រើជីវភាពប្រចាំរបស់ប្រជាជនលើទីផ្សារ
- សម្របសម្រួលការផ្គត់ផ្គង់សម្ភារប្រើប្រាស់ ចំណីអាហារ អង្ករ និងទំនិញយុទ្ធសាស្ត្រដទៃទៀតតាមការចាំបាច់ និងឱ្យបានទាន់ពេលវេលា
- ដោះស្រាយសំណូមពររបស់ប្រជាពលរដ្ឋទាក់ទងនឹងបរិមាណ យថាប្រភេទ និងថ្លៃទំនិញនៅលើទីផ្សារ
- រៀបចំរបាយការណ៍ និងរាយការណ៍ជូនប្រធានក្រុមការងារ
- បំពេញភារកិច្ចផ្សេងៗទៀត តាមការណែនាំរបស់ថ្នាក់ដឹកនាំក្រសួង។

**ប្រការ៣ _**

សមាជិកក្រុមការងារនេះត្រូវបំពេញភារកិច្ចរបស់ខ្លួន និងត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

**ប្រការ៤ _**

នាយកឧទ្ទកាល័យ គ្រប់អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋាន ប្រធានមន្ទីរពាណិជ្ជកម្មរាជធានី ប្រធានមន្ទីរពាណិជ្ជកម្មខេត្តកណ្តាល ប្រធានគ្រប់អង្គភាពពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៥កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន-សូរស័ក្តិ**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- គណៈកម្មការជាតិគ្រប់គ្រង និងដឹកនាំការអនុវត្តវិធានការបិទខ្ទប់
- ដូចប្រការ៤
- ឯកសារ កាលប្បវត្តិ